**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...០៤៧..អបស.មត

ថ្ងៃ..ពុធ..១១រោចខែទុតិយាសាឍឆ្នាំឆ្លូវ..ត្រីស័ក ព.ស ២៥៦៥..

រាជធានីភ្នំពេញ ថ្ងៃទី...០៤....ខែ..សីហា..ឆ្នាំ២០២១...

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជម្រាបមក**

- **ឯកឧត្តម លោកជំទាវ អគ្គនាយក នាយក មន្ទីរពេទ្យជាតិ**
- **លោក លោកស្រីប្រធានមជ្ឈមណ្ឌលជាតិ**
- **ឯកឧត្តម លោកជំទាវ ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត**
- **សេវាសុខាភិបាលឯកជន (មន្ទីរពេទ្យ មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរសម្ភព)**

**កម្មវត្ថុ:** ស្តីពីការរៀបចំចាត់ចែង និងអនុវត្តការទទួលយកអ្នកជំងឺព្យាបាលនៅតាមសេវាសាធារណៈ (មន្ទីរពេទ្យថ្នាក់ជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ស្រុក ខណ្ឌ មណ្ឌលសុខភាព និងសេវាសុខាភិបាលឯកជន(មន្ទីរពេទ្យ មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរសម្ភព)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងសុខាភិបាលសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អគ្គនាយក នាយក មន្ទីរពេទ្យជាតិ លោក លោកស្រីប្រធានមជ្ឈមណ្ឌលជាតិ ឯកឧត្តម លោកជំទាវ ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត និងលោក លោកស្រី ដែលជាម្ចាស់សេវាសុខាភិបាលឯកជន(មន្ទីរពេទ្យ មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរសម្ភព) ជ្រាបថា រយៈកាលកន្លងមកនេះ មានបាតុភាពបានកើតឡើងជារឿយៗ ដែលអ្នកជំងឺមានសភាពធ្ងន់ធ្ងរ បានទៅរកកន្លែងព្យាបាលនៅតាមសេវាសាធារណៈ(មន្ទីរពេទ្យរដ្ឋ) និងសេវាសុខាភិបាលឯកជន (គ្លីនិកឯកជន) បែរជាមិនទទួលយកពួកគាត់មកធ្វើការព្យាបាល ដែលធ្វើឱ្យជះឥទ្ធិពលមិនល្អមកលើក្រសួងសុខាភិបាល និងសេចក្តីថ្លៃថ្នូររបស់គ្រូពេទ្យ ដូចនេះក្រសួងសុខាភិបាលសូមធ្វើការណែនាំដូចខាងក្រោមនេះ ៖

1. ចំពោះមន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ ត្រូវតែប្រកាន់យកគោលការណ៍ទទួលសង្គ្រោះ ព្យាបាលអ្នកជំងឺជាដាច់ខាត ដោយអាចប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ក្នុងការញែកអ្នកជំងឺកូវីដ-១៩។ ក្នុងករណីដែលធ្វើតេស្តទៅឃើញអវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលតាមផ្នែក និងតាមបច្ចេកទេសព្យាបាលធម្មតា និងក្នុងករណីធ្វើតេស្តទៅឃើញវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនអ្នកជំងឺទៅបន្ទប់ដាច់ដោយឡែកសម្រាប់ព្យាបាលអ្នកជំងឺកូវីដ-១៩។ មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ ត្រូវមានលេខទូរស័ព្ទសម្រាប់ឱ្យអ្នកជំងឺមកពីខាងក្រៅធ្វើការទំនាក់ទំនង(មានក្នុងឧបសម្ព័ន្ធ)។
2. ចំពោះមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ស្រុក ខណ្ឌ និងមណ្ឌលសុខភាព ក៏ត្រូវតែប្រកាន់យកគោលការណ៍ទទួលសង្គ្រោះ ព្យាបាលអ្នកជំងឺជាដាច់ខាត ដោយអាចប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ក្នុងការញែកអ្នកជំងឺកូវីដ-១៩។ ក្នុងករណីធ្វើតេស្តទៅឃើញអវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលតាមផ្នែក និងតាមបច្ចេកទេសព្យាបាលធម្មតា និងក្នុងករណីធ្វើតេស្តទៅឃើញវិជ្ជមានកូវីដ-១៩ ត្រូវបញ្ជូនអ្នកជំងឺទៅបន្ទប់ដាច់ដោយឡែកសម្រាប់ព្យាបាលអ្នកជំងឺកូវីដ-១៩ ប្រសិនបើមន្ទីរពេទ្យបង្អែកណាគ្មានកន្លែងព្យាបាលជំងឺកូវីដ-១៩ ទេ ត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែករាជធានី ខេត្ត។ រាល់ការបញ្ជូនត្រូវធ្វើការទំនាក់ទៅលេខទូរស័ព្ទរបស់មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ដែលមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ ដោយប្រាប់ពីមូលហេតុនៃការបញ្ជូន និងស្ថានភាពរបស់អ្នកជំងឺដែលត្រូវបញ្ជូនឱ្យបានដឹងជាមុន។
3. ចំពោះមូលដ្ឋានសេវាសុខាភិបាលឯកជន (មន្ទីរពេទ្យ មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរសម្ភព) ត្រូវតែប្រកាន់យកគោលការណ៍ទទួលសង្គ្រោះ ព្យាបាលអ្នកជំងឺជាដាច់ខាត ដោយអាចប្រើប្រាស់តេស្តរហ័សរកអង់

ទីហៀនកូវីដ-១៩ ក្នុងការព្យាបាលអ្នកជំងឺកូវីដ-១៩ បើសង្ស័យថាអ្នកជំងឺមានជំងឺកូវីដ-១៩។ ក្នុងករណីធ្វើតេស្តទៅឃើញអវិជ្ជមានកូវីដ-១៩ ត្រូវទទួលយកអ្នកជំងឺព្យាបាលធម្មតា ទៅតាមបច្ចេកទេសព្យាបាល និងក្នុងករណីធ្វើតេស្តទៅឃើញវិជ្ជមានកូវីដ-១៩ ត្រូវដាក់អ្នកជំងឺក្នុងបន្ទប់ព្យាបាលដាច់ដោយឡែកសម្រាប់ព្យាបាលអ្នកជំងឺកូវីដ-១៩ (ប្រសិនបើមានការអនុញ្ញាតឱ្យព្យាបាលអ្នកជំងឺកូវីដ-១៩ ពីក្រសួងសុខាភិបាល) និងបញ្ជូនទៅមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ ឬមន្ទីរពេទ្យរដ្ឋដែលមានព្យាបាលអ្នកជំងឺកូវីដ-១៩ (ប្រសិនបើពុំមានការអនុញ្ញាតឱ្យព្យាបាលជំងឺកូវីដ-១៩ ពីក្រសួងសុខាភិបាល)។ ក្នុងករណីដែលម្ចាស់មូលដ្ឋានសេវាសុខាភិបាលឯកជនណា ដែលមិនអនុវត្តតាមការណែនាំនេះ ក្រសួងសុខាភិបាលនឹងមានវិធានការបិទមូលដ្ឋានសេវាសុខាភិបាលឯកជននោះ មិនអនុញ្ញាតឱ្យទទួលព្យាបាលអ្នកជំងឺតទៅទៀតឡើយ។

4. រាល់ករណីអ្នកជំងឺវិជ្ជមានកូវីដ-១៩ ដែលត្រូវបញ្ជូនទៅមណ្ឌលព្យាបាលកូវីដ-១៩ ត្រូវធ្វើការទំនាក់ទៅលេខទូរស័ព្ទរបស់មណ្ឌលព្យាបាលកូវីដ-១៩ ដែលមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ ដោយប្រាប់ពីមូលហេតុនៃការបញ្ជូន និងស្ថានភាពរបស់អ្នកជំងឺដែលត្រូវបញ្ជូនឱ្យបានដឹងជាមុន។

5. អនុគណៈកម្មការបច្ចេកទេស និងព្យាបាលកូវីដ-១៩ និងនាយកដ្ឋានមន្ទីរពេទ្យ ត្រូវត្រួតពិនិត្យ តាមដាន ការងារនេះជាប្រចាំ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ក្នុងករណីមានបាតុភាពមិនប្រក្រតីកើតឡើង។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** រៀបចំចាត់ចែងអនុវត្តតាមការណែនាំនេះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានពីខ្ញុំ។

ម៉ម_ប៊ុនហេង

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច តេជោ នាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋានគណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- អនុគណៈកម្មការបច្ចេកទេស និងព្យាបាលកូវីដ-១៩
  (ដើម្បីអនុវត្ត)
- រដ្ឋបាលរាជធានី ខេត្ត
  (ដើម្បីជូនជ្រាប)
- ឯកសារ-កាលប្បវត្តិ